

# តើការងារក្នុងក្ដីស្រមៃ

## របស់ខ្ញុំនៅឯណា?

**លីអូណែល (Lionel) ទើបតែបានបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រសីល្បៈទូទៅ។** គាត់មិនមានមហិចតាទេ ប៉ុន្តែ គាត់គ្រាន់តែចង់បានការងារមួយដែលធ្វើឲ្យគាត់ពេញចិត្ត និងមានន័យ។ ការងារនោះមិនចាំបាច់ទាល់តែមានប្រាក់ខែច្រើនទេ ប៉ុន្តែ កុំឲ្យតែធ្វើឲ្យគាត់ខ្វះខាតទៅបានហើយ។ អ្វីដែលសំខាន់នោះ គឺឲ្យតែគាត់ពេញចិត្តនឹងធ្វើការ។ ដោយឡែក លីអូណែលមិនដឹងថាខ្លួនឯងចង់ធ្វើការងារអ្វី នៅឡើយទេ។ គាត់បានមើលការផ្សព្វផ្សាយជ្រើសរើសបុគ្គលិក ប៉ុន្តែ គ្មានការងារអ្វីដែលគាត់ចាប់អារម្មណ៍ឡើយ។ យ៉ាងណាក៏ដោយ គាត់នៅតែគិតថានឹងមានការងារស្របតាមក្ដីស្រមៃរបស់គាត់នៅកន្លែងណាមួយជាពិត។ គាត់គ្រាន់តែនៅមិនដឹងថា ការងារនោះជាអ្វីនៅឡើយ។

ស៊ូយីន(Suyin) មានការដឹងច្បាស់លាស់ អំពីការងាររបស់នាងជាងលីអូណែល។ នាងកំពុងចាប់ចិត្តនឹងការងារថតរូប ហើយក៏កំពុងធ្វើការជាអ្នកថតរូប ឲ្យកាសែតក្នុងស្រុកមួយផងដែរ។ ប៉ុន្តែ ការងារនោះគួរឲ្យធុញទ្រាន់ណាស់ ពីព្រោះភាគច្រើននៃភារៈកិច្ចរបស់នាង គឺចាំផ្ដិតយករូបភាពនៃព្រឹត្តិការណ៍ដ៏គួរឲ្យធុញ ក្នុងសហគមន៍ ហើយចៅហ្វាយរបស់នាងមិនបានផ្ដល់ឱកាស ឲ្យនាងរីកចម្រើនសោះ។ តើនាង

គួរតែលារឈប់ពីការងារ ហើយចាកចេញទៅតស៊ូធ្វើការ ដោយខ្លួនឯងវិញឬ? នាងចង់ធ្វើដំណើរទៅគ្រប់ទីកន្លែង ក្នុងតំបន់នោះ ដើម្បីផ្ដិតយករូបភាពនៃក្រុមពលករអន្តោប្រវេសន៍ ដែលកំពុងជួបការរំលោភបំពាន។ នោះគឺជាក្ដីស្រមៃរបស់នាង។ ប៉ុន្តែ នាងនឹងជួបបញ្ហាធំ រឿងលុយកាក់។ តើអ្នកណាជាអ្នកឲ្យប្រាក់ខែនាង?

ទន្ទឹមគ្នានោះដែរ ណារិត (Narit) រកបានការងារតាមក្ដីស្រមៃរបស់គាត់។ គាត់តែងតែចង់ធ្វើជាវិស្វករយន្តហោះ ព្រោះគាត់ចូលចិត្តយន្តហោះ និងគ្រឿងម៉ាស៊ីន។ ដូច្នេះ គាត់បានខិតខំសិក្សា ព្រមទាំងប្រឡងបានពន្ទុល្អ ផ្នែកវិស្វករគ្រឿងម៉ាស៊ីនយន្តហោះ នៅឯសាកលវិទ្យាល័យ ហើយក៏រកបានការងារដូចចិត្ត គឺជាការងារមានប្រាក់កំរៃខ្ពស់ ដោយធ្វើជាអ្នកជួសជុលម៉ាស៊ីនយន្តហោះប្រតិកម្ម ដែលមានបច្ចេកវិទ្យាទំនើប។ ទោះជាយ៉ាងណាក្ដី រយៈពេលពីរបីខែក្រោយមកណារិតបានកត់សំគាល់ឃើញថា អស់ទាំងភាពរំភើបរីករាយបានរលាយបាត់អស់ ដោយសារការងារមានឯកសារច្រើនមិនចេះចប់មិនចេះហើយ ព្រមទាំងកាលវិភាគដ៏ចង្អៀតច្រើនស្អេកស្កះផង ហើយជាច្រើនដងគាត់ត្រូវធ្វើការរហូតដល់យប់ជ្រៅ និងនៅថ្ងៃចុងសប្ដាហ៍ថែមទៀតផង។ គាត់ក៏គិតថា ការងារដែលគាត់ស្រមៃមិនគួរណា វល់ខ្លាំងយ៉ាងនេះសោះ។

## អាជីពៈ ជាការងារអ្វីដែលយើងពេញចិត្តតាមចាប់ ពេញមួយជីវិត

### តើលោកអ្នកធ្លាប់ឃើញគេជួបរឿងដូចនេះដែរឬទេ?

រឿងខាងលើនេះ សុទ្ធតែជារឿងពិត ហើយបានឆ្លុះបញ្ចាំង អំពីអ្វីដែលមនុស្សភាគច្រើនចង់បាន នោះគឺអាជីព ដែលយើងពេញចិត្ត។ មនុស្សជាច្រើនបានស្វែងរកការងារ ក្នុងក្ដីស្រមៃ បន្ទាប់ពីរៀនចប់ ហើយសង្ឃឹមថា នឹងបានធ្វើការងារដែលធ្វើឲ្យខ្លួនស្កប់ចិត្ត និងមាន

ន័យ។ បន្ទាប់មក យើងក៏ចំណាយពេលភាគច្រើន នៃជីវិតរបស់យើង ដើម្បីឈោងទៅរកគោលដៅនេះ។

អ្នកខ្លះប្រហែលជាចង់ក្លាយជានាយកប្រតិបត្តិកំពូល ដែលមានប្រាក់ខែច្រើន ហើយមានការទទួលខុសត្រូវជាច្រើន ក្នុងភាពជាអ្នកដឹកនាំ។ អ្នកខ្លះស្រមៃចង់ក្លាយជាសិល្បៈករ ឬតន្ត្រីករដ៏ល្បីល្បាញ។ អ្នកខ្លះទៀតចង់សម្រេចបានកិច្ចការដែលមានប្រយោជន៍ ដូចជាការផលិតជាថ្នាំ ឬបច្ចេកវិទ្យាសម្រាប់សង្គ្រោះជីវិត។ ហើយនៅមានអ្នកខ្លះទៀតចង់ចំណាយជីវិតរបស់ខ្លួន ដើម្បីការអ្វីដែលខ្លួនមានជំនឿយ៉ាងមុតមាំ ដូចជាការធ្វើការងារជួយដល់ជនអនាថា ឬការអភិរក្សបរិស្ថានជាដើម។

មានមនុស្សតិចតួចណាស់ ដែលកម្រនឹងទទួលបានជោគជ័យ ក្នុងការស្វែងរកអាជីពដែលខ្លួនពេញចិត្ត តែមនុស្សភាគច្រើននៅតែព្យាយាម ដេញតាមចាប់អាជីពដ៏ឥតខ្ចោះណាមួយ។ យើងនឹងមានការលំបាកក្នុងការជ្រើសរើសការងារ ហើយបន្ទាប់មក យើងក៏មានការខ្វល់ខ្វាយមិនដឹងថា យើងបានធ្វើការសម្រេចចិត្តត្រឹមត្រូវឬក៏អត់។ យើងខិតខំធ្វើការងារច្រើនម៉ោង ដោយសង្ឃឹមថានឹងមានគេទទួលស្គាល់យើង ហើយនឹងទទួលបាននូវរង្វាន់ សម្រាប់ការខំប្រឹងប្រែងរបស់យើង។ អ្នកខ្លះថែមទាំងផ្លាស់ប្តូរផែនការសម្រាប់អាពាហ៍ពិពាហ៍ និងសម្រាប់កូន ហើយខំលះបង់ពេលវេលាជាមួយគ្រួសារ និងមិត្តភក្តិ ឬលះបង់ការកម្សាន្តសប្បាយ និងចំណង់ចំណូលចិត្ត ដើម្បីអាជីពរបស់ខ្លួនទៀតផង។

មានមនុស្សតិចតួចណាស់ ដែលកម្រនឹងទទួលបានជោគជ័យ ក្នុងការស្វែងរកអាជីពដែលខ្លួនពេញចិត្ត តែមនុស្សភាគច្រើននៅតែព្យាយាម ដេញតាម ចាប់អាជីពដ៏ឥតខ្ចោះណា មួយ។

មានអ្នកខ្លះបែរជារស់នៅ ដើម្បីអាជីពរបស់ខ្លួនទៅវិញ។ ពួកគេ

បានចំណាយពេលវេលាភាគច្រើននៃជីវិត ដើម្បីដេញតាមចាប់គោលដៅរបស់ខ្លួន ហើយសុខចិត្តបោះបង់ចោលអ្វីៗគ្រប់យ៉ាង ឲ្យតែបានទៅដល់គោលដៅនោះ។ ជួនកាល ការនេះបាននាំឲ្យខូចសុខភាពផ្លូវចិត្ត ផ្លូវអារម្មណ៍ និងដល់រូបកាយថែមទៀតផង ឬនាំឲ្យមានការបាក់បែក ឬការបាត់បង់ភាពស្និទ្ធស្នាល ក្នុងទំនាក់ទំនង ក្នុងក្រុមគ្រួសារ និងក្នុងចំណោមមិត្តភក្តិជាដើម។

ហេតុអ្វីបានជាការងាររបស់យើងមានន័យសំខាន់ ចំពោះយើងយ៉ាងនេះ? ហេតុអ្វីបានជាយើងចំណាយពេលវេលា និងកំឡាំងច្រើនដល់ថ្នាក់ហ្នឹង ក្នុងការឈោងចាប់អាជីព ក្នុងក្តីស្រមៃរបស់យើង ហើយហេតុអ្វី បានជាយើងតែងតែស្វែងរករបស់អ្វីដែលប្រសើរជាងអ្វីៗដែលខ្លួនមានស្រាប់ រហូតអីចឹង?

## អ្វីដែលយើងពិតជាចង់បានបំផុត

**មនុស្សមិនគ្រាន់តែស្វែងរកលុយ និងភាពជោគជ័យប៉ុណ្ណោះទេ។** នៅពេលយើងដេញតាមអាជីពណាមួយ យើងកំពុងតែស្វែងរកអ្វីដែលសំខាន់ ដូចជាឱកាសដើម្បីប្រើប្រាស់អំណោយទាន និងជំនាញរបស់យើង ការឆ្លងកាត់ដំណាក់កាលដែលធ្វើឲ្យយើងរំភើបចិត្ត ព្រមទាំងការទទួលស្គាល់ និងរង្វាន់ សម្រាប់ការប្រឹងប្រែងរបស់យើង ហើយជាពិសេសគឺឱកាសជះឥទ្ធិពលមកលើអ្នកដទៃ និង ផ្លាស់ប្តូរអ្វីមួយ។

ជាការពិតណាស់ ការមានគោលដៅដូចនេះ មិនមែនជាទង្វើរខុសឆ្គងទេ។ គោលដៅទាំងនោះ គឺជាផ្នែកមួយនៃបំណងប្រាថ្នាធំរបស់យើង ក្នុងនាមជាមនុស្ស ហើយការទាំងនោះជំរុញយើង ឲ្យខិតខំធ្វើការងារ និងធ្វើឲ្យខ្លួនយើងកាន់តែប្រសើរឡើង។ តែគួរឲ្យសោកស្តាយណាស់ គោលដៅទាំងនេះអាចដាក់សម្ពាធធ្ងន់ពេក មកលើយើង នៅក្នុងការខំប្រឹងបំពេញការងារ ឬស្វែងរកអាជីពដែលល្អឥតខ្ចោះ។ ប៉ុន្តែយើងកម្រនឹងរកបានអាជីព ឬការងារ ដែលធ្វើឲ្យយើងស្កប់ចិត្ត ឲ្យបាន

ឥតខ្ចោះ។

តាមពិត មនុស្សភាគច្រើនមិនត្រឹមតែមិនសប្បាយចិត្ត នៅកន្លែងធ្វើការប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងមិនស្កប់ចិត្តនឹងអាជីពរបស់ខ្លួនថែមទៀតផង។ ការស្ទាបស្ទង់មតិនៅឆ្នាំ២០១៤ បានរកឃើញថា នៅក្នុងបណ្តាប្រទេសខ្លះ នៅទ្វីបអាស៊ី ពាក់កណ្តាលនៃអ្នកធ្វើការ មិនសប្បាយចិត្តនឹងការងាររបស់ខ្លួនទេ ហើយពីរភាគបីនៃអ្នកដែលមានការងារធ្វើ បាននិយាយថា ពួកគេត្រៀមខ្លួន លារឈប់ពីការងារ ប្រសិនបើពួកគេអាចរកបានការងារណា ដែលទទួលបានប្រាក់ច្រើនជាង ឬមានអត្ថប្រយោជន៍ជាង។

ការស្វែងរកអាជីពរបស់យើងមិនទាន់បញ្ចប់ ត្រឹមពេលដែលយើងរកបានការងារទីមួយនោះឡើយ។ មនុស្សជាច្រើននៅតែបន្តស្វែងរករបស់អ្វីដែលប្រសើរជាងអ្វីៗដែលខ្លួនមានស្រាប់ ជារៀងរហូតអស់មួយជីវិត។ ជាញឹកញាប់ យើងតែងតែឆ្ងល់ថា តើមានការងារអ្វីផ្សេងដែលប្រសើរជាងការងារដែលយើងកំពុងធ្វើទេ ពុំនោះទេតើយើងអាចនឹងទទួលបានជោគជ័យជាងមុន នៅក្នុងកិច្ចការដែលយើងកំពុងធ្វើឬទេ? ការដេញតាមការងាររបស់យើង ហាក់ដូចជាមិនចេះចប់មិនចេះហើយសោះ។

ជាការពិតណាស់ មានអ្នកខ្លះរកបានការងារ ស្របតាមក្តីស្រមៃរបស់ពួកគេមែន។ ប៉ុន្តែ អ្នកខ្លះយល់ឃើញថា ពួកគេត្រូវតែធ្វើការលះបង់ដ៏ធំ ដើម្បីទទួលបានអ្វីដែលពួកគេចង់បាន។ អ្នកខ្លះទៀត យល់ឃើញថា ក្តីស្រមៃរបស់ពួកគេមិនអស្ចារ្យ ដូចអ្វីដែលពួកគេធ្លាប់រំពឹងទុកនោះទេ គឺមិនខុសពី ណារិតឡើយ។ រីឯអ្នកផ្សេងទៀត រកបានការងារដែលហាក់ដូចជា

ជាការពិតណាស់ មានអ្នកខ្លះរកបានការងារស្របតាមក្តីស្រមៃរបស់ពួកគេមែន។ ប៉ុន្តែ អ្នកខ្លះយល់ឃើញថា ពួកគេត្រូវតែធ្វើការលះបង់ដ៏ធំ ដើម្បីទទួលបានអ្វីដែលពួកគេចង់បាន។

> អាជីព មិនអាចបំពេញតម្រូវការដ៏ជ្រាលជ្រៅបំផុតរបស់យើងបានទេ ទោះជាវាមានជោគជ័យយ៉ាងណាក៏ដោយ។

មានផលប្រយោជន៍ច្រើន ឬមានប្រាក់កំរៃខ្ពស់ តែពួកគេបែរជាចាយវាយប្រាក់ទាំងអស់ ទៅលើការអ្វី "ដែលមិនទំនងសោះ" ដូចជាការធ្វើដំណើរទូទាំងពិភពលោកជាដើម។

ហេតុអ្វីពួកគេហ៊ានលះបង់ច្រើនដល់ម្លេះ សម្រាប់ការអ្វីដែលហាក់ដូចជាមានប្រយោជន៍តិចដូច្នេះ? នេះប្រហែលមកពី ដោយសារអាជីព មិនអាចបំពេញតម្រូវការដ៏ជ្រាលជ្រៅបំផុតរបស់យើងបាន ទោះជាវាមានជោគជ័យយ៉ាងណាក៏ដោយ។

## តម្រូវការដ៏ជ្រាលជ្រៅបំផុតរបស់យើង

**សូមចំណាយពេលបន្តិច ដើម្បីគិតអំពីការអ្វីខ្លះ ដែលពិតជាបានបណ្ដាលចិត្តមនុស្ស** ឲ្យខំដេញតាមចាប់អាជីពរបស់ខ្លួន នោះលោកអ្នកអាចរកឃើញ មូលហេតុរួមផ្សំមួយចំនួន។ លោកអ្នកនឹងឃើញថា ពួកគេបានដេញតាមចាប់អាជីពណាមួយ ដោយសារការចង់បាន ដែលមានច្រើនជាងតម្រូវការ ៖

**ភាពស្កប់ចិត្ត** : យើងទាំងអស់គ្នាសុទ្ធតែមានក្ដីសុបិនចង់បានសុភមង្គល ក្នុងជីវិត។ យើងចង់ចំណាយពេលវេលា និងកម្លាំងរបស់យើង នៅក្នុងការងារអ្វីដែលយើងចូលចិត្ត និងធ្វើឲ្យយើងមានអារម្មណ៍ល្អ។ វាអាចជាការងារដែលនាំមកនូវភាពសប្បាយរីករាយ ឬជាការដេញតាមបុព្វហេតុដែលយើងបានដាក់ចិត្តជឿ ឬក៏ជាការសម្រេចនូវការឆ្លងកាត់ឧបសគ្គផ្ទាល់ខ្លួន។

**ភាពមានសារៈសំខាន់** : យើងចង់ស្វែងរកអត្ថន័យ នៅក្នុងការងាររបស់យើង ព្រោះនៅទីបំផុត យើងចង់ដឹងថា យើងរស់នៅដើម្បី

គោលបំណងអ្វី។ យើងចង់ដឹងថា ហេតុអ្វីយើងមានវត្តមាននៅលើផែនដីនេះ ហើយតើយើងអាចធ្វើអ្វី ដើម្បីឲ្យបានការទទួលស្គាល់ និងរង្វាន់ សម្រាប់អំណោយទាន ជំនាញ និងការប្រឹងប្រែងរបស់យើង។ អ្នកខ្លះស្វែងរកការងារ ដែលធ្វើឲ្យមានការផ្លាស់ប្តូរ នៅក្នុងជីវិតអ្នកដទៃ ហើយការនេះនឹងនាំឲ្យពួកគេមានអារម្មណ៍ថា ខ្លួនរស់នៅមានន័យ នៅពេលដែល គេទទួលស្គាល់តម្លៃនៃការរួមចំណែករបស់ពួកគេ។

**សន្តិសុខ** : យើងចង់បានអាជីពមួយដែលមានភាពយូរអង្វែង។ ប្រសិនបើការងាររបស់យើងមានអនាគតល្អ ហើយស្ថាប័នដែលយើងធ្វើការបម្រើ មានការរីកចម្រើនទៀត នោះយើងនឹងមានទំនុកចិត្ត នៅក្នុងការខំប្រឹងធ្វើការងារ ដោយដឹងថាយើងក៏នឹងអាចបន្តរីកចម្រើនឡើង និងកាន់តែជោគជ័យ ផងដែរ។ ការដែលសំខាន់បំផុតនោះគឺ យើងអាចមានទំនុកចិត្តថា យើងនិងក្រុមគ្រួសាររបស់យើងនឹងទទួលបានការផ្គត់ផ្គង់ យ៉ាងសមរម្យ។

សាច់ឈាមរបស់យើង មានតម្រូវការទាំងអស់នេះ ជាធម្មតា តែតម្រូវការទាំងនេះ ក៏បានឆ្លុះបញ្ចាំងឲ្យយើងដឹងថា យើងជានរណា ហើយយើងចង់ក្លាយជាមនុស្សបែបណា។ មនុស្សជាច្រើនព្យាយាមបំពេញតម្រូវការទាំងនេះ នៅក្នុងអាជីពរបស់ខ្លួន។ ប៉ុន្តែ មានការងារ ឬអាជីពតិចណាស់ដែលអាចបំពេញតាមតម្រូវការទាំងអស់នេះ យ៉ាងគាប់ចិត្ត។ ផ្ទុយទៅវិញ ជាញឹកញាប់ យើងច្រើនតែ រសាប់រសល់ ហើយហត់នឿយ ដោយខំស្វែងរករបស់ដែលល្អជាងអ្វីៗដែលខ្លួនមានស្រាប់។ តើមកហេតុអ្វីទៅ?

អាជីពរបស់យើងមិនអាចផ្តល់ឲ្យ នូវភាពស្កប់ចិត្ត ភាពមានសារៈសំខាន់ និងសន្តិសុខ ដែលយើងត្រូវការទេ ព្រោះវាអាស្រ័យទៅលើកត្តាជាច្រើន ដែលយើងគ្មានសមត្ថភាពគ្រប់គ្រងបាន។ ការធ្លាក់ចុះនៃសេដ្ឋកិច្ច ការកែប្រែរចនាសម្ព័ន្ធថ្មីនៅក្នុងក្រុមហ៊ុន និងការផ្លាស់ប្តូរផតឈប់ឈរខាងផ្នែកបច្ចេកវិជ្ជា និងសង្គម សុទ្ធតែអាចជាកត្តា ដែលធ្វើឲ្យការងារល្អបំផុត បាត់បង់ទៅ ក្នុងរយៈពេលដ៏ខ្លី។ និយាយរួម ទាំង

អាជីព និងការងារ សុទ្ធតែមានភាពបណ្ដោះអាសន្ន។

ហេតុនេះហើយ នៅទីបំផុត មនុស្សជាច្រើនក៏បានដឹងខ្លួនថា ការស្វែងរកអាជីពដែលខ្លួនពេញចិត្ត មានពេញទៅដោយភាពមិនច្បាស់លាស់ និងការខកចិត្ត គឺមិនខុសពីលីអូណែល ស៊ូយីន និងណារិតឡើយ។ យើងស្វែងរកភាពស្កប់ចិត្ត និងការសម្រេចបំណងប្រាថ្នា ប៉ុន្តែ បែរជាមានភាពនឿយណាយ និងមិនសប្បាយចិត្តទៅវិញ។ អ្នកខ្លះរកបានអាជីពល្អ តែមានអារម្មណ៍ថា ខ្វះអ្វីមួយជានិច្ច។ អ្នកខ្លះទៀតសុខចិត្តបោះបង់ចោលអ្វីៗគ្រប់យ៉ាង ដើម្បីអាជីពរបស់ខ្លួន ចុងក្រោយទើបដឹងថា លទ្ធផលមិន សមនឹងឲ្យពួកគេលះបង់សោះ។ តើហេតុអ្វី?

> អាជីពរបស់យើងមិនអាចផ្ដល់ឲ្យ នូវភាពស្កប់ចិត្ត សារៈសំខាន់ និងសន្តិសុខ ដែលយើងត្រូវការទេ ព្រោះវាអាស្រ័យទៅលើកត្តាជាច្រើន ដែលយើងគ្មានសមត្ថភាគ្រប់គ្រងបាន។

តើយើងកំពុងស្វែងរកការសម្រេចបំណងប្រាថ្នា នៅកន្លែងខុសទេដឹង? តើមានជម្រើសណាផ្សេងទៀត ដែលអាចបំពេញតម្រូវការដ៏ជ្រាលជ្រៅបំផុតរបស់យើងដែរឬទេ?

## ការស្វែងរកជម្រើសផ្សេង

ជាការពិតណាស់ មនុស្សបានបែរទៅរករបស់ជាច្រើន ក្រៅពីអាជីពរបស់ពួកគេ ដើម្បីបំពេញតម្រូវការជាមូលដ្ឋានទាំងនេះ ប៉ុន្តែ ដំណោះស្រាយល្អបំផុត គឺមាននៅក្នុងអង្គបុគ្គលមួយរូប មិនមែននៅក្នុងអ្វីណាមួយឡើយ។ អង្គបុគ្គលនោះ មានលក្ខណៈសម្បត្តិសំខាន់ចាំបាច់បំផុតមួយចំនួន សម្រាប់បំពេញតម្រូវការរបស់យើងយ៉ាងល្អឥតខ្ចោះ ដែលមនុស្សទូទៅមិនអាចធ្វើបាន ៖

**ការដឹងអំពីអ្វីៗទាំងអស់** : ដើម្បីឲ្យអាចដឹងថា មានការអ្វី

ខ្លះដែលអាចបំពេញតម្រូវការ ដ៏ជ្រាលជ្រៅបំផុតរបស់យើងបាន អង្គបុគ្គលរូបនេះ ត្រូវតែមានប្រាជ្ញាសព្វគ្រប់ ក្នុងការដឹកនាំផ្លូវយើងយ៉ាងត្រឹមត្រូវ។ អង្គបុគ្គលរូបនេះត្រូវតែមានការយកចិត្តទុកដាក់ខ្ពស់បំផុត ហើយចង់ជួយយើង ឲ្យអាចធ្វើការសម្រេចចិត្ត និងចាប់ផ្តើមធ្វើសកម្មភាពបានត្រឹមត្រូវ ទើបយើងអាចរកបាននូវការស្កប់ចិត្តពិតប្រាកដនៅក្នុងការអ្វីដែលយើងកំពុងធ្វើនោះ។

**មានពេញដោយក្តីស្រឡាញ់** : ដើម្បីជួយយើងឲ្យអាចរកឃើញគុណតម្លៃ អង្គបុគ្គលដែលជ្រាបដឹងគ្រប់ទាំងអស់នេះ ត្រូវតែជាអ្នកដែលស្រឡាញ់យើង និងឲ្យតម្លៃយើងជាមុនសិន ដោយផ្តល់ឲ្យយើងនូវគោលបំណង និងអត្តសញ្ញាណដ៏ពិត គឺប្រៀបដូចជាឪពុកម្តាយ ដែលប្រកបដោយក្តីស្រឡាញ់ ដែលតែងតែឲ្យកូនដឹងថា ខ្លួនមានចំណែក និងការធានា។

**នៅរស់គង់ជានិច្ច** : ដើម្បីប្រទានឲ្យយើងមានសន្តិសុខ អង្គបុគ្គលនោះ ត្រូវតែជាអ្នកដែលយើងអាចពឹងពាក់បានទាំងស្រុង គឺជាបុគ្គលដែលពិតជាអាចផ្តល់មកនូវភាពស្កប់ចិត្ត និងភាពមានសារៈសំខាន់ គ្រប់ពេលវេលាទាំងអស់។ យើងត្រូវការការធានាថា អង្គបុគ្គលនោះ តែងតែមានវត្តមាននៅជិតយើងជានិច្ច ហើយតែងតែគិតពីប្រយោជន៍យើង មិនថាមានរឿងអ្វីកើតឡើងនោះឡើយ។

តើនរណាមានលក្ខណៈសម្បត្តិទាំងអស់ ដែលបានរៀបរាប់ខាងលើ? ប្រាកដណាស់ អ្នកនោះ មិនមែនជាអ្នកដែលខ្សោយ ដែលអាចប្រែប្រួល ឬដែលអាចស្លាប់នោះឡើយ។ អ្នកនោះ ត្រូវតែមានលក្ខណៈជាអង្គបុគ្គលដែលពិសេសខុសគេ។

សូមពិចារណាអំពីព្រះអាទិករចុះ។ គឺមានតែទ្រង់ទេ ដែលមានលក្ខណៈសម្បត្តិទាំងអស់នេះ។

សាវ័កប៉ុល ដែលជាអ្នកជឿព្រះ បានពណ៌នាអំពីព្រះអាទិករថា "ដ្បិតព្រះដែលបង្កើតលោកីយ នឹងរបស់សព្វសារពើ ព្រះអង្គនោះ ទ្រង់

ជាព្រះអម្ចាស់នៃស្ថានសួគ៌ នឹងផែនដី ទ្រង់មិនគង់នៅក្នុងវិហារដែលដៃមនុស្សបានធ្វើទេ។ ក៏មិនបាច់មានដៃមនុស្សបំរើទ្រង់ ដូចជាទ្រង់ត្រូវការអ្វីនោះផងដែរ ដ្បិតគឺទ្រង់ដែលផ្គត់ផ្គង់ដោយព្រះអង្គទ្រង់ ឲ្យគ្រប់ទាំងអស់មានជីវិត មានដង្ហើមគ្រប់ជំពូក។ ទ្រង់បានបង្កើតមនុស្សគ្រប់សាសន៍ពីឈាមតែ១ឲ្យបាននៅពេញលើផែនដី ព្រមទាំងសំរេចកំណត់ពេលវេលា ដែលបានតាំងជាមុន នឹងព្រំទីលំនៅរបស់គេគ្រប់គ្នា ដើម្បីឲ្យគេស្វែងរកព្រះ ក្រែងគេនឹងរកទ្រង់ឃើញ ដោយខំរាវរកមែននោះទេដឹង ទោះបើទ្រង់មិនគង់ឆ្ងាយពីយើងនិមួយៗក៏ដោយ។ ដ្បិតគឺដោយសារទ្រង់ហើយ ដែលយើងរាល់គ្នាបានរស់ កំរើក ហើយមាននៅផង″ (កិច្ចការ ១៧:២៤-២៨)។

ពីព្រោះព្រះបានបង្កើតចក្រវាលទាំងមូល នោះទ្រង់ក៏ជ្រាបអំពីអ្វីៗគ្រប់យ៉ាង គ្មានចន្លោះ រួមទាំងយើងផង។ ទ្រង់ស្គាល់យើងយ៉ាងច្បាស់បំផុត។ ទ្រង់ជ្រាបអំពីអ្វីដែលយើងចាប់អារម្មណ៍ និងអ្វីដែលយើងត្រូវការ ព្រមទាំងជួយយើងឲ្យរកឃើញការសម្រេចបំណងប្រាថ្នាដ៏ពិតរបស់យើង។

ហើយក្នុងនាមជាព្រះដែលបានបង្កើតយើងមក ទ្រង់ស្រឡាញ់យើងម្នាក់ៗ ហើយសព្វព្រះទ័យនឹងជួយយើងគ្រប់គ្នា។ ទ្រង់មានពេញដោយសេចក្តីស្រឡាញ់ ហើយទ្រង់យកព្រះហឫទ័យទុកដាក់ ចំពោះជីវិតរបស់យើងម្នាក់ៗ និងចំពោះអ្វីដែលកើតឡើងចំពោះយើង។ ទ្រង់ជ្រាបអំពីចិត្ត គំនិត និងអស់ទាំងទង្វើរបស់យើង។

លើសពីនេះទៅទៀត ព្រះទ្រង់គង់នៅអស់កល្បជានិច្ច ហើយក៏មិនចេះប្រែប្រួល ជាពិសេសទ្រង់មិនដែលធ្វើឲ្យយើងខកចិត្តឡើយ។ ទ្រង់មិនដែលផ្លាស់ប្តូរព្រះទ័យ ហើយក៏មិនដែលក្បត់សន្យាផង គឺមិនដូចជាមនុស្សទេ។ ទ្រង់មានព្រះបន្ទូលថា "អញនេះជាព្រះអម្ចាស់ ហើយអញមិនចេះប្រែប្រួលឡើយ″ (ម៉ាឡាគី ៣:៦)។ ដូច្នេះ យើងតែងតែអាចដឹងច្បាស់ថា ទ្រង់គង់នៅជាមួយជានិច្ច ហើយអាចពឹងអាងលើទ្រង់ជានិច្ចផង។

ប្រសិនបើព្រះទ្រង់មានលក្ខណៈសម្បត្តិទាំងអស់នេះហើយ នោះទ្រង់មិនដែលគង់ឆ្ងាយ ហើយក៏មិនដែលខាននឹងយកព្រះហឫទ័យទុកដាក់នឹងយើង ម្តងណាឡើយ។ យើងអាចមានទំនាក់ទំនងដ៏ស្និទ្ធស្នាលជាមួយទ្រង់ ដូចគ្នានឹងការទំនាក់ទំនងដែលយើងមានជាមួយនឹងឪពុកម្តាយ ឬមិត្តភក្តិរបស់យើងដូច្នោះដែរ។ តើលោកអ្នកចង់ទទួលនូវសេចក្តីស្រឡាញ់របស់ទ្រង់ឬទេ?

ប្រសិនបើព្រះទ្រង់មានលក្ខណៈសម្បត្តិទាំងអស់នេះហើយ នោះទ្រង់មិនមែនជាដែលគង់ឆ្ងាយ ហើយក៏មិនដែលខាននឹងយកព្រះហឫទ័យទុកដាក់នឹងយើង ម្តងណាឡើយ។

## **អ្វីដែលពិតជាសំខាន់**

**ការដេញតាមចាប់អាជីពរបស់យើង** អាចនាំឲ្យនឿយណាយ ព្រោះនៅទីបញ្ចប់យើងនឹងនៅតែបន្តស្វែងរកអ្វីមួយផ្សេង ដែលជារបស់ក្នុងលោកិយ ហើយក៏អាចនិយាយបានថា យើងហាក់បីដូចជាកំពុងដេញតាមចាប់ខ្យល់ដូច្នោះដែរ។ យើងអាចលះបង់ពេលវេលាទាំងអស់ព្រមទាំងកម្លាំងរបស់យើង ដើម្បីស្វែងរកការងារល្អមួយ ហើយទោះយើងធ្វើការងារនោះ បានល្អយ៉ាងណាក៏ដោយ ក៏យើងនៅតែមានអារម្មណ៍ថា មិនទាន់សម្រេចតាមបំណងប្រាថ្នាដដែល។

ព្រះទ្រង់សព្វព្រះទ័យឲ្យយើង មានទស្សនៈមួយដែលខុសពីមុន ដោយគិតថា ទោះអាជីពរបស់យើង មានភាពសមរម្យ ក្នុងជីវិតរបស់យើងហើយក៏ដោយ ក៏មិនមែនមានតែអាជីពនោះទេ ដែលសំខាន់ចំពោះយើង ហើយវាក៏មិនមែនជាអ្វីដែលសំខាន់បំផុតនោះដែរ។ យើងមិនចាំបាច់ត្រូវព្រួយបារម្ភថា យើងត្រូវលះបង់អ្វីៗគ្រប់យ៉ាង ដើម្បីការងារក្នុងក្តីស្រមៃរបស់យើង ដែលក្រោយមកបានត្រឹមតែនាំឲ្យយើងខកចិត្តនោះឡើយ។ ផ្ទុយទៅវិញ យើងនឹងដឹងអំពីរបៀបរស់នៅ ស្រប

តាម "ផែនការរបស់ព្រះ" ដែលធំប្រសើរជាងផែនការរបស់យើង ហើយដឹងអំពីរបៀបធ្វើការសម្រេចចិត្តត្រឹមត្រូវ មិនថាតែយើងទើបតែចាប់ផ្តើមអាជីពរបស់យើង ឬកំពុងដោះស្រាយបញ្ហាចំពោះមុខ នៃការងារដំបូងរបស់យើង ឬក៏កំពុងស្វែងរកគោលបំណងរបស់យើង នៅឯកន្លែងធ្វើការ និងនៅក្នុងជីវិតក្តី។

នៅទីបញ្ចប់ មានតែនៅក្នុងព្រះជាម្ចាស់ប៉ុណ្ណោះ ដែលយើងអាចរកឃើញគោលបំណងដ៏ពិត នៃជីវិត ហើយមានតែនៅក្នុងទ្រង់តែ១គត់ ដែលយើងអាចចាប់ផ្តើមរកឃើញភាពស្កប់ចិត្ត ភាពមានសារៈសំខាន់ និងសន្តិសុខផងដែរ។ អ្វីដែលយើងត្រូវធ្វើគឺបែរមករកទ្រង់ ព្រមទាំងជឿ និងទុកចិត្តទ្រង់។

> នៅទីបញ្ចប់ មានតែនៅក្នុងព្រះជាម្ចាស់ប៉ុណ្ណោះ ដែលយើងអាចរកឃើញនូវគោលបំណងដ៏ពិត នៃជីវិត ហើយមានតែនៅក្នុងទ្រង់តែ១គត់ ដែលយើងអាចចាប់ផ្តើមរកឃើញភាពស្កប់ចិត្ត ភាពមានសារៈសំខាន់ និងសន្តិសុខផងដែរ។

តើលោកអ្នកបានបែរមករកព្រះជាម្ចាស់ហើយឬនៅ?

ប្រសិនបើលោកអ្នកចង់ស្វែងយល់បន្ថែមអំពីព្រះជាម្ចាស់ សូមទំនាក់ទំនងព្រះវិហារ ដែលនៅជិតលោកអ្នក ដែលនៅទីនោះ គេអាចបកស្រាយចម្ងល់ទាំងប៉ុន្មានដែលលោកអ្នកមាន។ ម្យ៉ាងទៀត លោកអ្នកអាចស្វែងរកព្រះគម្ពីរមួយក្បាល ដែលនឹងប្រាប់លោកអ្នកអំពីព្រះជាម្ចាស់ និងអំពីរបៀបដែលទ្រង់ប្រទានឲ្យលោកអ្នកមានភាពស្កប់ចិត្ត ភាពមានសារៈសំខាន់ និងសន្តិសុខដែលលោកអ្នកត្រូវការ។

យើងខ្ញុំ ដែលជាក្រុមការងារនៃអង្គការនំម៉ាណាប្រចាំថ្ងៃ ក៏សូមស្វាគមន៍លោកអ្នកជានិច្ច។ លោកអ្នកក៏អាចស្វែងយល់ព្រះបន្ទូលព្រះបន្ថែម និងស្វែងរកសៀវភៅ និងអត្ថបទដទៃទៀត តាមអាស័យដ្ឋាន : www.khmer-odb.org/ds។

ប្រែសម្រួលជាភាសាខ្មែរ ដោយ លោក លី ប៊ុនថា

ពិនិត្យផ្ទៀងផ្ទាត់ និងកែសម្រួលអត្ថបទដោយ : លោក ឯក សត្យា

បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤ ដោយការអនុញ្ញាតិ និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល (បានដកស្រង់ ដោយរក្សាអក្ខរាវិរុទ្ធដើម)។

រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2018 ODB Ministries ( website: www.odb.org )

ចេញផ្សាយដោយ : ODB Cambodia ( email: cambodia@odb.org, Tell: 087 233 907,

website: http://khmer-odb.org, Facebook page : https://www.facebook.com/khmer.odb )